ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ធនាគារជាតិ នៃ កម្ពុជា**

លេខ..........................................................

**មតិសំណេះសំណាល**
**លោកជំទាវបណ្ឌិត ជា សិរី ទេសាភិបាល ធនាគារជាតិនៃកម្ពុជា**
**ថ្លែងក្នុងពិធីបើកសិក្ខាសាលាស្តីពី ការរៀបចំផែនការអាជីព និងការជ្រើសរើសជំនាញសិក្សា**
**សម្រាប់សិស្សថ្នាក់ទី១២ ឆ្នាំសិក្សា ២០២៤-២០២៥ ចំនួន ៥៨៨នាក់ ក្នុងស្រុកសន្ទុក**
**ខេត្តកំពង់ធំ ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២៥**

- ឯកឧត្តម លោកជំទាវ លោក-លោកស្រី ក្រុមការងារថ្នាក់កណ្តាល ថ្នាក់ខេត្ត ថ្នាក់ស្រុក
- លោក **ឡុង គីសឹង** អភិបាលស្រុកសន្ទុក
- លោក **ខៀវ រឿន** ប្រធានមជ្ឈមណ្ឌលការងារខេត្តកំពង់ធំ នៃទីភ្នាក់ងារជាតិមុខរបរ និងការងារ
- លោកនាយក-នាយករង លោកគ្រូ-អ្នកគ្រូ ប្អូនៗសិស្សានុសិស្សទាំងអស់ ជាទីស្រលាញ់រាប់អាន

ថ្ងៃនេះ ខ្ញុំមានសេចក្តីសោមនស្ស ដោយបានចូលរួមក្នុងកម្មវិធីបើកសិក្ខាសាលាស្តីពី **ការរៀបចំផែនការអាជីព និងការជ្រើសរើសជំនាញសិក្សា** សម្រាប់ក្មួយៗសិស្សថ្នាក់ទី១២ ចំនួន ៥៨៨រូប នៅក្នុងវិទ្យាល័យទាំង៣ របស់ស្រុកសន្ទុកយើងនេះ រួមមាន៖ ១/-វិទ្យាល័យ ហ៊ុន សែន ភ្នំសន្ទុក ២/-វិទ្យាល័យតាំងក្រសាំង និង ៣/-វិទ្យាល័យកំពង់ថ្ម។

ជាបឋម ខ្ញុំសូមថ្លែងអំណរគុណចំពោះឯកឧត្តម-លោកជំទាវ លោក-លោកស្រី និងក្មួយៗទាំងអស់ ដែលបានចំណាយពេលវេលាដ៏មានតម្លៃចូលរួមសិក្ខាសាលានាព្រឹកនេះ និងជាពិសេសសូមថ្លែងអំណរគុណចំពោះទីភ្នាក់ងារជាតិមុខរបរនិងការងារ នៃក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្រុមការងារយុវជនធនាគារជាតិនៃកម្ពុជាដែលបានសហការរៀបចំសិក្ខាសាលានេះឡើងយ៉ាងល្អប្រពៃ។

ការរៀបចំផែនការអាជីព និងជ្រើសរើសជំនាញសិក្សា គឺជាជំហានសំខាន់មួយក្នុងការកំណត់ទិសដៅអនាគតក្នុងជីវិតរបស់ក្មួយៗ។ ការជ្រើសរើសជំនាញសិក្សាឱ្យបានត្រឹមត្រូវ និងការកំណត់គោលដៅអាជីពច្បាស់លាស់ អាចជួយឱ្យក្មួយៗផ្តោតពេលវេលាក្នុងការក្រេបជញ្ជក់ចំណេះដឹង និងចាប់យកជំនាញឯកទេសមួយ ដែលអាចប្រកួតប្រជែងក្នុងទីផ្សារការងារ និងអភិវឌ្ឍន៍អាជីពយូរអង្វែង។ ដូច្នេះ ការវាយតម្លៃយ៉ាងម៉ត់ចត់ និងរៀបចំផែនការមុនពេលសម្រេចចិត្ត គឺជាគន្លឹះនាំឱ្យទទួលបានភាពរីកចម្រើនក្នុងពេលអនាគត។

សិក្ខាសាលាថ្ងៃនេះ ត្រូវបានរៀបចំឡើងក្នុងគោលបំណងឱ្យក្មួយៗ ស្វែងយល់អំពីចំណុចគន្លឹះនៃការរៀបចំផែនការអាជីព និងការជ្រើសរើសជំនាញសិក្សា ដែលមាន ៥ចំណុច ដូចខាងក្រោម៖

១/- ស្វែងយល់ពីខ្លួនឯងឱ្យបានច្បាស់លាស់ តាមរយៈការពិនិត្យលើចំណុចខ្លាំង ចំណុចខ្សោយ ចំណាង់ចំណូលចិត្ត ជំនាញ គុណតម្លៃ និងបុគ្គលិកលក្ខណៈរបស់ខ្លួន



ប្រអប់សំបុត្រលេខ ២៥, ឡូតិ៍លេខ ៤៨ ផ្លូវលេខ ១០២ កែងនឹងផ្លូវលេខ ១៩ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ , ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ / ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

២/- ស្វែងយល់ពីអាជីព និងមុខរបរ ដែលសមស្របតាមជំនាញឯកទេសផ្សេងៗគ្នា
៣/- ស្វែងយល់ពីតម្រូវការកម្លាំងពលកម្មតាមជំនាញឯកទេស និងទិន្នន័យនៃប្រាក់បៀវត្សរ៍ សម្រាប់ពេលបច្ចុប្បន្ន និងអនាគត ទាំងកម្រិតក្នុងប្រទេស និងកម្រិតតំបន់
៤/- ស្វែងយល់ពីលទ្ធភាព កត្តាជំរុញ និងកត្តារារាំង ចំពោះការសម្រេចគោលដៅរបស់ខ្លួន និង
៥/- រៀបចំផែនការអាជីព និងការសិក្សារបស់ខ្លួនឱ្យបានសមស្រប ទៅតាមរយៈកាលខ្លី ឬវែង។

ក្រុមការងារនឹងផ្តល់ជាសៀវភៅកម្រងសំណួរដើម្បីជួយក្មួយៗ ស្វែងយល់ពីខ្លួនឯង ដោយវិភាគលើជំនាញ ចំណូលចិត្ត គុណតម្លៃ និងបុគ្គលិកលក្ខណៈរបស់ក្មួយៗ ដើម្បីជួយណែនាំផែនការអាជីព និងការសិក្សាដែលស្របតាមតម្រូវការទីផ្សារការងារបច្ចុប្បន្ន និងអនាគត។ ទន្ទឹមនេះ ក្រុមការងារយុវជនធនាគារជាតិនៃកម្ពុជាដែលធ្លាប់ទទួលបានអាហារូបករណ៍ទៅសិក្សានៅបរទេស ក៏នឹងចែករំលែកពីបទពិសោធ និងបញ្ហាប្រឈមដែលពួកគាត់បានជួបប្រទះក្នុងការដាក់ពាក្យ ការសម្ភាស ការត្រៀមខ្លួន និងការសិក្សានៅបរទេស ជូនក្មួយៗទាំងអស់ផងដែរ។ រហូតមកដល់បច្ចុប្បន្ន មានអាហារូបករណ៍បរទេសជាច្រើនសម្រាប់កម្រិតថ្នាក់បរិញ្ញាបត្រ នៅបណ្តាប្រទេស ដូចជា ជប៉ុន កូរ៉េ ចិន ថៃ វៀតណាម និងកម្រិតថ្នាក់អនុបណ្ឌិតសិក្សានៅបណ្តាប្រទេស ដូចជា អូស្ត្រាលី នូវែលសេឡង់ ជប៉ុន អង់គ្លេស អាល្លឺម៉ង់ អាមេរិក និងប្រទេសក្នុងសហភាពអឺរ៉ុបមួយចំនួនទៀត។

សូមក្មួយៗកុំខ្មាស់អៀនក្នុងការសួរមតិយោបល់ និងបទពិសោធន៍ពីពួកគាត់។ ក្មួយៗអាចស្វែងរកអ្នកប្រឹក្សាយោបល់ដែលទុកចិត្តបាន ដូចជា លោកគ្រូ-អ្នកគ្រូ ឬតាមរយៈការចូលរួមវេទិកាសាធារណៈស្តីពីឱកាសការងារផ្សេងៗ ឱ្យបានញឹកញាប់ ក្មួយៗនឹងអាចទទួលបានព័ត៌មានកាន់តែច្រើន ដូច្នេះ ការសម្រេចចិត្តរបស់ក្មួយៗក៏នឹងកាន់តែសុក្រឹត និងត្រឹមត្រូវផងដែរ។ ដើម្បីទទួលបានជោគជ័យក្នុងការសិក្សា ឯកឧត្តមទេសាភិបាលកិត្តិយសតែងបានលើកឡើងនូវអង្គ ៤ គឺ សុ ចិ បុ លិ។ សុ ៖ សំដៅដល់ការស្តាប់ ត្រូវត្រង់ត្រាប់ស្តាប់យ៉ាងយកចិត្តទុកដាក់ និងប្រុងប្រយ័ត្ន។ ចិ ៖ សំដៅដល់ការគិត ត្រូវត្រិះរិះពិចារណាឱ្យម៉ត់ចត់ និងគ្រប់ជ្រុងជ្រោយ។ បុ ៖ សំដៅដល់ការសួរ ត្រូវហ៊ានសួរសំណួរ សូមកុំខ្មាស់អៀនសម្រាប់ការសួរសំណួរ សំណួរទាំងអស់សុទ្ធតែល្អៗ និងមានសារៈប្រយោជន៍ សួរកាន់តែច្រើន ទទួលព័ត៌មានកាន់តែច្រើន និងគ្រប់ជ្រុងជ្រោយ នោះការសម្រេចចិត្តក៏កាន់តែត្រឹមត្រូវ។ ចុងក្រោយ លិ ៖ កត់ត្រានូវព័ត៌មានទាំងឡាយដែលទទួលបាននៅថ្ងៃនេះ។ (រឿងបុរសឪពុក និងកូននាំលាទៅលក់ ដកស្រង់ពីសៀវភៅគតិលោក និងរឿងអនិកជនបើកក្រុមហ៊ុនសម្អាតនៅប្រទេសកាណាដា)

**ឯកឧត្តម លោកជំទាវ លោក-លោកស្រី លោកគ្រូ-អ្នកគ្រូ និងក្មួយៗទាំងអស់ ជាទីស្រលាញ់រាប់អាន!**

សុខសន្តិភាព និងស្ថិរភាពនយោបាយរបស់ប្រទេសជាតិ គឺជាមូលដ្ឋានគ្រឹះដ៏រឹងមាំ ដែលបានពង្រឹងជំនឿទុកចិត្តរបស់វិនិយោគិន ដៃគូពាណិជ្ជកម្ម ដៃគូអភិវឌ្ឍន៍ និងភាគីពាក់ព័ន្ធនានា ឱ្យចូលរួមយ៉ាងសកម្មក្នុងការអភិវឌ្ឍសេដ្ឋកិច្ច-សង្គម ជាពិសេស បានគាំទ្រដល់ការអនុវត្តកម្មវិធីកែទម្រង់ស៊ីជម្រៅរបស់រាជរដ្ឋាភិបាល ឱ្យសម្រេចបានជាបន្តបន្ទាប់ប្រកបដោយប្រសិទ្ធភាពនិងផ្លែផ្កាខ្ពស់។ ជាមួយគ្នានេះដែរ ក្រោមគោលនយោបាយបើកទូលាយសេដ្ឋកិច្ច និងបង្កើនសមាហរណកម្មទៅក្នុងតំបន់និងពិភពលោក ភាពប្រសើរឡើងនៃស្ថានភាពសេដ្ឋកិច្ចពិភពលោកបានរួមចំណែកយ៉ាងសំខាន់ក្នុងការគាំទ្រសសរស្តម្ភសេដ្ឋកិច្ចកម្ពុជាគឺ ការនាំចេញ វិស័យទេសចរណ៍ និងសំណង់។

ក្រោមដំបូលសុខសន្តិភាពដែលជាកេរ្តិ៍មរតកដឹកនាំរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា និងជាប្រធានគណបក្សប្រជាជនកម្ពុជា រាជរដ្ឋាភិបាលនីតិកាលទី៧ ដែលដឹកនាំដោយ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** បាននិងកំពុងដឹកនាំប្រទេសប្រកបដោយភាពស្វាហាប់ ឈ្លាសវៃ ព្រមទាំងពង្រឹង និងពង្រីកសមាហរណកម្មជាតិ និងអន្តរជាតិ ដើម្បីបន្តបេសកកម្មដ៏ពិសិដ្ឋក្នុងការរក្សាសុខសន្តិភាព ជំរុញកំណើនសេដ្ឋកិច្ច និងគរពូនសមិទ្ធផលថ្មីៗបន្តទៀត ដើម្បីឆ្លើយទៅនឹងតម្រូវការដ៏ពិតប្រាកដរបស់ប្រជាពលរដ្ឋ។

ដើម្បីសម្រេចឱ្យបានមហិច្ឆតាដ៏ធំធេងនេះ រាជរដ្ឋាភិបាលដែលដឹកនាំដោយ**សម្តេចធិបតី ហ៊ុន ម៉ាណែត** បានដាក់ឱ្យអនុវត្តសកម្មភាពការងារយ៉ាងសកម្មតាមផែនទីចង្អុលផ្លូវរបស់ខ្លួន គឺ **«យុទ្ធសាស្ត្របញ្ចកោណ»** ដែលជាកម្មវិធីនយោបាយសម្រាប់ការកសាង និងការពារមាតុភូមិឆ្នាំ២០២៣-២០២៨។ រាជរដ្ឋាភិបាលនីតិកាលទី ៧ នៃរដ្ឋសភា បានកំណត់យកអាទិភាពគន្លឹះចំនួន ៥ «មនុស្ស ផ្លូវ ទឹក ភ្លើង និងបច្ចេកវិទ្យា» ក្នុងយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ ដោយនៅក្នុងបញ្ចកោណយុទ្ធសាស្ត្រទី ១ ផ្តោតជាចម្បងលើការអភិវឌ្ឍមូលធនមនុស្ស ដែលជាលក្ខខណ្ឌចាំបាច់មិនអាចខ្វះបានសម្រាប់ជំរុញពិពិធកម្ម កំណើនសេដ្ឋកិច្ច និងការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចជាតិ ប្រកបដោយបរិយាបន្ន និងភាពធន់។ ក្នុងន័យនេះ រាជរដ្ឋាភិបាលផ្តោតលើអាទិភាពចំនួន ៥ សម្រាប់កសាងមូល-ធនមនុស្សរឹងមាំ រួមមាន៖ ១/- ការពង្រឹងគុណភាពវិស័យអប់រំ កីឡា វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ២/- ការបណ្តុះបណ្តាលជំនាញបច្ចេកទេស និងវិជ្ជាជីវៈ ៣/- ការលើកកម្ពស់សុខភាព និងសុខុមាលភាពប្រជាជន ៤/- ការពង្រឹងប្រព័ន្ធគាំពារសង្គម និងប្រព័ន្ធស្បៀង និង ៥/- ការពង្រឹងភាពជាពលរដ្ឋក្នុងសង្គម ដែលមានអារ្យធម៌ខ្ពស់ប្រកបដោយសីលធម៌ សមធម៌ និងបរិយាបន្ន។

នៅពេលប្រទេសជាតិកាន់តែរីកចម្រើន តម្រូវការទីផ្សារការងារកាន់តែទូលំទូលាយ ជាពិសេសជំនាញវិជ្ជាជីវៈផ្សេងៗ ដែលអាចឆ្លើយតបទៅនឹងបរិការណ៍សេដ្ឋកិច្ចបច្ចុប្បន្ន ដូចជា ជំនាញបច្ចេកទេស ភាសាអង់គ្លេស និងកុំព្យូទ័រ ជាដើម។ ស្របតាមយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ របស់រដ្ឋាភិបាលដែលបានកំណត់យកអាទិភាពគន្លឹះទី១ គឺ**មនុស្ស** ដោយបានផ្តោតសំខាន់លើការកសាងនិងអភិវឌ្ឍមូលធនមនុស្សប្រកបដោយគុណភាព សមត្ថភាព ជំនាញវិជ្ជាជីវៈច្បាស់លាស់ គំនិតច្នៃប្រឌិត និងភាពប្រកួតប្រជែងខ្ពស់ដើម្បីសម្រេចឱ្យបាននូវគោលដៅ "ពលរដ្ឋម្នាក់មានជំនាញមួយយ៉ាងតិចប្រចាំជីវិត" កាលពីថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០២៣ សម្តេចធិបតី **ហ៊ុន ម៉ាណែត** បានប្រកាសដាក់ឱ្យអនុវត្តជាផ្លូវការកម្មវិធីបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងបច្ចេកទេសសម្រាប់យុវជនមកពីគ្រួសារក្រីក្រ និងគ្រួសារងាយរងហានិភ័យ។ ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ បានកំណត់យកវិស័យអាទិភាពចំនួន ១០ និងមុខជំនាញចំនួន ៣៨ ដើម្បីបណ្តុះបណ្តាលយុវជនគោលដៅចំនួន ១លាន៥សែននាក់ ដោយមិនបង់ថ្លៃ និងទទួលប្រាក់ឧបត្ថម្ភ ២៨ម៉ឺនរៀលក្នុងមួយខែ។ គិតត្រឹមថ្ងៃទី២៥ មេសា ២០២៥ អ្នកដែលបានចុះឈ្មោះចូលរៀនប្រមាណ ១១,៣ម៉ឺននាក់ និងសិស្សកំពុងរៀន និងបានបញ្ចប់ការសិក្សាមានប្រមាណ ៧,២ម៉ឺននាក់ ហើយអ្នកដែលទទួលបានការងារបន្ទាប់ពីបញ្ចប់ប្រមាណ១,៦ម៉ឺននាក់។

រយៈពេល ៤ខែដើមឆ្នាំ២០២៥នេះ កម្ពុជាទទួលបានគម្រោងវិនិយោគចំនួន ២២៥គម្រោង មានទុនវិនិយោគប្រមាណ ៣,២ពាន់លានដុល្លារ និងអាចបង្កើតការងារបានចំនួនប្រមាណ ១៥ម៉ឺនកន្លែង។

ថ្មីៗនេះ កាលពីថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០២៥ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន និង លោកជំទាវ ប៊ុន រ៉ានី** បានផ្តល់ដីទំហំ២ហិកតា ដែលមានតម្លៃជាង១០លានដុល្លារជូនក្រសួងកិច្ចការនារី ដើម្បីកសាងអន្តេវាសិកដ្ឋានសម្រាប់និស្សិតជាស្ត្រីក្រីក្រមកពីបណ្តាខេត្ត មកបន្តការសិក្សានៅរាជធានីភ្នំពេញ ដែលមាន១២០បន្ទប់ អាចស្នាក់នៅបាន៥០០នាក់ និងមានសម្រាប់ពិនិត្យជម្ងឺនឹងគ្រូពេទ្យប្រចាំការផងដែរ។

ខ្លឹមសារជំនួយស្មារតីបន្ថែម

១/- តាមរយៈសិក្ខាសាលាថ្ងៃនេះ ខ្ញុំសង្ឃឹមថាក្មួយៗនឹងទទួលបានគតិច្រើនជាទុនក្នុងការពិចារណាសម្រេចចិត្តបន្តការសិក្សាលើមុខជំនាញ ដែលខ្លួនឯងចូលចិត្ត និងមានទេពកោសល្យ។ ត្រូវមានគោលការណ៍ក្នុងជីវិតឱ្យបានប្រាកដនិងច្បាស់លាស់។ **អភិក្រមរបស់សម្តេចធិបតី គឺ រៀនឱ្យចេះ រៀនឱ្យចប់ និងឱ្យមានការងារធ្វើ។** តាមខ្ញុំដឹង បច្ចុប្បន្ន គ្រឹះស្ថានឧត្តមសិក្សាសរុបមានចំនួន ១២៨ (ទាំងរដ្ឋ និងឯកជន) កំពុងបណ្តុះបណ្តាលលើមុខជំនាញជាង ៨០មុខជំនាញ។ ដូច្នេះ ក្មួយៗមានជម្រើសច្រើន ក្នុងការសម្រេចចិត្ត ប៉ុន្តែត្រូវចងចាំថា ជម្រើសទាំងនោះ ជាការឆ្លើយតបទៅនឹងចំណូលចិត្តផ្ទាល់ខ្លួន និងទេពកោសល្យរបស់ខ្លួនដែរ (មិនមែនជាការសម្រេចចិត្ត**របស់សង្សារ ឬមិត្តភក្តិ**នោះទេ)។ ខ្ញុំជឿថា ធ្លាប់មានករណីនេះកើតឡើង ឧទាហរណ៍ ដឹងថាសង្សារសម្រេចចិត្តទៅរៀនពេទ្យ ដូច្នេះដើម្បីបានជួបមុខគេរាល់ថ្ងៃ ក៏សម្រេចចិត្តទៅរៀនពេទ្យដែរទាំងដែលខ្លួនឯងមិនដែលចូលចិត្តពេទ្យផងនោះ។

២/- ធនាគារជាតិនៃកម្ពុជាក៏បាននិងបន្តលើកកម្ពស់ការអប់រំដល់ក្មួយៗទាំងអស់ តាមរយៈការឧបត្ថម្ភវគ្គបំប៉នបន្ថែមជារៀងរាល់ឆ្នាំសម្រាប់សិស្សប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ (ថ្នាក់ទី១២) ការបញ្ជ្រាបចំណេះដឹងផ្នែកហិរញ្ញវត្ថុដល់សិស្សានុសិស្សក្នុងកម្មវិធីសិក្សាចំណេះដឹងទូទៅពីថ្នាក់ទី១ ដល់ទី១២ និងយុទ្ធនាការអប់រំខ្លីៗ ដូចជា ការបោះពុម្ពសៀវភៅ "តោះ! និយាយពីលុយ" ដែលលើកកម្ពស់ការយល់ដឹងលើការគ្រប់គ្រងប្រាក់កាសប្រកបដោយភាពវៃឆ្លាត ដូចជា ការរៀបចំផែនការចំណូល-ចំណាយ ការសន្សំ និងការប្រើប្រាស់លុយកម្ចីឱ្យបានត្រឹមត្រូវ ជាដើម។ ទន្ទឹមនេះ ធនាគារជាតិនៃកម្ពុជាក៏បានឧបត្ថម្ភនិងបំពាក់កុំព្យូទ័រជាច្រើនគ្រឿង នៅក្នុងបន្ទប់សិក្សាកុំព្យូទ័រ ព្រមទាំងផ្តល់ជូននូវការបង្រៀនកុំព្យូទ័រ ដល់ក្មួយៗ ដែលគ្រូបង្រៀនសុទ្ធសឹងជាមន្ត្រីផ្នែកព័ត៌មានវិទ្យា ដែលមានបទពិសោធន៍បម្រើការងារយូរឆ្នាំមកហើយ។ លើសពីនេះ ធនាគារជាតិនៃកម្ពុជាក៏កំពុងសស្រាក់សស្រាំក្នុងការជ្រើសរើសគ្រូបង្រៀនភាសាអង់គ្លេស ដែលជាមន្ត្រីរបស់ធនាគារជាតិនៃកម្ពុជាផងដែរ ដែលសុទ្ធសឹងមានសញ្ញាបត្របរិញ្ញាបត្រផ្នែកបង្រៀនភាសាអង់គ្លេសតែម្តង ដើម្បីផ្តល់នូវការបំពាក់បំប៉នភាសាអង់គ្លេសបន្ថែមដល់ក្មួយៗ ជាទុនសម្រាប់ត្រៀមចូលមហាវិទ្យាល័យ ឬបន្តសិក្សាជំនាញបច្ចេកទេសផ្សេងៗ។

៣/- បច្ចេកវិទ្យាមានភាពរីកចម្រើនលឿននិងខ្ពស់ ហើយក្មួយៗមានស្មាតហ្វូនសឹងគ្រប់គ្នា មានបណ្តាញសង្គមប្រើប្រាស់គ្រប់គ្នាដូចជា Tiktok, Facebook ជាដើម ប៉ុន្តែ វាក៏ជាអាវុធមុខពីរដែរបើសិនយើងប្រើប្រាស់វាក្នុងផ្លូវខុស។ សូមក្មួយៗគិតពិចារណាផង មុននឹង Like ឬ Share ឬ comment ថាតើព័ត៌មានទាំងនោះពិតឬក្លែងក្លាយ ជាព័ត៌មានបំពុលសង្គម ឬយ៉ាងណា។ បើតាមបែបព្រះពុទ្ធសាសនាវិញ គឺ សូមមើលអ្វីៗដោយប្រើបញ្ញា ចំពោះព្រឹត្តការណ៍កើតក្នុង

សង្គម។

៤/- ចង់ឱ្យប្រទេសយើងម្ចាស់ការគ្រប់វិស័យ ទាល់តែកូនខ្មែរចេះគ្រប់វិស័យ។ បើមិនអញ្ចឹងទេ យើងត្រូវពឹងគេរហូត។ បើដូចកាលជំនាន់កូវីដ ១៩ មិនអាចឆ្លងព្រំដែន យើងចប់។ ប៉ុន្តែដោយសារយើងពឹងសមត្ថភាពកូនខ្មែរជាវេជ្ជបណ្ឌិត គិលានុបដ្ឋាយិកា ជាអ្នកព្យាបាលដែលសង្គ្រោះប្រជាពលរដ្ឋយើងបាន។ ការបណ្តុះបណ្តាលធនធាន(មនុស្ស)ខ្លួនឯង គឺជាការពង្រឹងឯករាជ្យភាព និងការស្នេហាជាតិ ទឹកដី តាមរយៈការពង្រឹងសមត្ថភាព និងទទួលខុសត្រូវរបស់កូនខ្មែរ។

៥/- ប្រទេសមួយអាច មានអារ្យធម៌រុងរឿងបាន ទាល់តែមាន មូលធនមនុស្សពូកែ ។ ការកសាងសង្គមជាតិមួយ ឱ្យរុងរឿងទាល់តែមាន ស្ថិរភាព សង្គតិភាព និងការពូនជ្រំសមិទ្ធផល រក្សាសមិទ្ធផលចាស់ បង្កើនសមិទ្ធផល ថ្មី ប្រមូលផ្តុំ កម្លាំង និងចំណេះដឹង ចំណេះធ្វើ ពីមួយជំនាន់ទៅមួយជំនាន់។ ប្រសិនបើសង្គមមួយ ដែលរវល់តែឈ្លោះគ្នា បែកបាក់គ្នា និងមានសង្គ្រាមរ៉ាំរ៉ៃ ផ្លាស់ប្តូររបបគ្រប់គ្រងឥតឈប់ សង្គមនោះពិតជាគ្មានពេលវេលាក្នុងការ កសាងហេដ្ឋារចនាសម្ព័ន្ធចាំបាច់ កសាងស្ថាប័ន និងកសាងសមត្ថភាពនៃមូលធនមនុស្សរបស់ខ្លួនបានឡើយ ហើយសង្គមនោះប្រហែលជាត្រូវខាតបង់ធនធានយ៉ាងច្រើន ដើម្បីគាំទ្រដល់ការប្រយុទ្ធតតាំងគ្នា ជាជាងការកសាងជាតិ ។

៦/- ផ្លូវដើររបស់ក្មួយៗនៅវែងឆ្ងាយណាស់ បើគិតចាប់ពីចំណុចត្រង់នេះ រហូតក្មួយៗទទួលបានការងារធ្វើ និងមានសេរីភាពនិងស្វ័យភាពហិរញ្ញវត្ថុបានដោយខ្លួនឯង សូមក្មួយៗបន្តព្យាយាមសិក្សារៀនសូត្រ ជៀសឱ្យឆ្ងាយពីក្រុមក្មេងទំនើង និងគ្រឿងញៀន និងចូលរួមគោរពច្បាប់ចរាចរណ៍ទាំងអស់គ្នា ដើម្បីសុវត្ថិភាពផ្ទាល់ខ្លួន និងសហគមន៍យើង ព្រមទាំងចូលរួមថែរក្សាអនាម័យទីធ្លាសាលា ដើម្បីទទួលបានបរិស្ថានសិក្សាល្អ។

## ឯកឧត្តម លោកជំទាវ លោក-លោកស្រី លោកគ្រូ-អ្នកគ្រូ និងក្មួយៗទាំងអស់

ជាថ្មីម្តងទៀត ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះក្រុមការងារទាំងអស់ ដែលបានចូលរួមសហការរៀបចំសិក្ខាសាលានេះ ក៏ដូចជាឯកឧត្តម-លោកជំទាវ លោក-លោកស្រី លោកនាយក-នាយករង និងក្មួយៗជាសិស្សថ្នាក់ទី១២ ទាំងអស់ដែលបានចូលរួមក្នុងសិក្ខាសិលានេះ ហើយសង្ឃឹម ជឿជាក់យ៉ាងមុតមាំថា ក្មួយៗទាំងអស់នឹងជ្រើសរើសជំនាញសិក្សាឱ្យបានត្រឹមត្រូវ ហើយខិតខំប្រឹងប្រែងរៀនសូត្របន្តការសិក្សាថ្នាក់ឧត្តមសិក្សា និងថ្នាក់ក្រោយៗទៀត ដើម្បីកសាងខ្លួនឱ្យស័ក្តិសមជាពលរដ្ឋល្អ មន្ត្រីរាជការល្អ បុគ្គលិកល្អ ដោយប្រើនូវជំនាញ ចំណេះដឹងពិតប្រាកដរបស់ខ្លួន ប្រកបដោយមនសិការវិជ្ជាជីវៈ ការទទួលខុសត្រូវក្នុងការងារ សីលធម៌ល្អ ដើម្បីចូលរួមកសាងជាតិយើងទាំងអស់គ្នា ។

លោក-លោកស្រី និងក្មួយៗទាំងអស់ ប៉ុន្មានសប្តាហ៍មកនេះ បានទទួលព័ត៌មានពីភាពតានតឹងនៅតាមបណ្តាយព្រំដែនរវាងកម្ពុជា និងថៃ។ ផ្តើមចេញពីការប៉ះទង្គិចប្រដាប់អាវុធរវាងទាហ៊ានថៃ និងកម្ពុជា ហើយឈានដល់ការបិទខ្ទប់ព្រំដែន និងកាត់បន្ថយម៉ោងបើកច្រកព្រំដែនរវាងប្រទេសទាំងពីរ ដែលធ្វើឱ្យមានការរាំងស្ទះដល់ការនាំចូល-នាំចេញទំនិញ និងផលប៉ះពាល់ទៅលើពលករចំណាកស្រុករបស់កម្ពុជានៅប្រទេសថៃផងដែរ។ ក្រោមការដឹកនាំដ៏ឈ្លាសវៃរបស់**សម្តេចធិបតី ហ៊ុន ម៉ាណែត** ដើម្បីសម្រាលបន្ទុក

ហិរញ្ញវត្ថុសម្រាប់បងប្អូនប្រជាពលករ ដែលត្រឡប់មកពីថៃវិញដែលមានជាប់ជំពាក់កម្ចីជាមួយគ្រឹះស្ថានធនាគារ ឬមីក្រូហិរញ្ញវត្ថុ សមាគមធនាគារនៅកម្ពុជា និងសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជានឹងជួយសម្រួលតាមរយៈការរៀបចំឥណទានឡើងវិញ ក្នុងករណីមានតម្រូវការជាក់ស្តែង និងវិធានការមុតស្រួចទាន់ពេលវេលានានាដទៃទៀត ដែលដាក់ចេញដោយរាជរដ្ឋាភិបាលនាពេលកន្លងមកផងដែរ។ខ្ញុំសូមអំពាវនាវដល់លោក-លោកស្រី និងក្មួយៗទាំងអស់ បន្តគាំទ្រគោលនយោបាយរាជរដ្ឋាភិបាល និងជឿជាក់លើការដឹកនាំរបស់**សម្តេចធិបតី ហ៊ុន ម៉ាណែត** ដើម្បីប្រទេសជាតិយើងបន្តទទួលបានសុខសន្តិភាព ស្ថិរភាពសង្គម ជាពិសេសបន្តទទួលបានការអភិវឌ្ឍសេដ្ឋកិច្ចសង្គម។

ជាទីបញ្ចប់ ខ្ញុំសូមជូនពរ ឯកឧត្តម លោកជំទាវ លោក-លោកស្រី និងក្មួយៗសិស្សានុសិស្សទាំងអស់ សូមទទួលបាននូវសេចក្តីសុខ សេចក្តីចម្រើន និង ជោគជ័យគ្រប់ភារកិច្ច ព្រមទាំងសមប្រកបដោយពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ និងសូមជូនពរក្មួយៗទាំងអស់ទទួលបាន ជោគជ័យក្នុងការប្រលងបញ្ចប់សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ (ថ្នាក់ទី១២) នាខែសីហាខាងមុខនេះ។ (ឱ្យបាននិទ្ទេស A ទាំងអស់គ្នា)។ នៅឆ្នាំនេះ ក៏ដូចជាឆ្នាំមុនៗ ធនាគារជាតិនៃកម្ពុជានឹងផ្តល់អាហារូបករណ៍ជូនសិស្សរៀនពូកែនិទ្ទេស A ទាំងអស់នៅទូទាំងខេត្តកំពង់ធំយើងនេះ អោយទទួលបានអាហារូបករណ៍ពេញពីវិទ្យាស្ថានសិក្សាបច្ចេកទេសធនាគារ (ទាំងថ្លៃសិក្សា និងការស្នាក់នៅ) ។ ចំពោះសិស្សទទួលបាននិទ្ទេស B ធនាគារជាតិនៃកម្ពុជានឹងផ្តល់អាហារូបករណ៍ឥតបង់ថ្លៃសិក្សាតែប៉ុណ្ណោះ។ ដោយឡែក ធនាគារជាតិនៃកម្ពុជាក៏នឹងផ្តល់អាហារូបករណ៍សម្រាប់ការសិក្សានៅបណ្តាគ្រឹះស្ថានសិក្សារដ្ឋ និងការស្នាក់នៅដោយឥតគិតថ្លៃ នៅអន្តេវាសិកដ្ឋានរបស់វិទ្យាស្ថានសិក្សាបច្ចេកទេសធនាគារ ដល់សិស្សដែលរៀនពូកែ និងមានការខិតខំប្រឹងប្រែងរៀនសូត្រ ប៉ុន្តែពុំមានលទ្ធភាពបន្តការសិក្សា ដោយសារស្ថានភាពគ្រួសារក្រីក្រ ខ្សត់ខ្សោយខ្លាំង ដូចនេះ សូមលោកគ្រូ-អ្នកគ្រូ លោកនាយក នាយិកាសាលា មេត្តាពិនិត្យពីលទ្ធផល និងស្ថានភាពសិស្ស ដើម្បីដាក់ស្នើមកធនាគារជាតិនៃកម្ពុជា ដើម្បីពិនិត្យ និងសម្រេចផ្តល់អាហារូបករណ៍ តាមស្ថានភាពជាក់ស្តែងរបស់សិស្ស។

ខ្ញុំសូមប្រកាសបើកសិក្ខាសាលាតម្រង់ទិស ស្តីពី **ការរៀបចំផែនការអាជីព និងការជ្រើសរើសជំនាញសិក្សា** ចាប់ពីពេលនេះតទៅ។

**សូមអរគុណ!**